ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សុន្ទរកថា

## ឯកឧត្តម អ៊ឹម ឈុនលឹម ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
## និងជាប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

*(រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១២)*

» *សូមគោរព ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ!*

» *ឯកឧត្តមឯកអគ្គរាជទូត ឯកឧត្តមឯកអគ្គរដ្ឋទូត តំណាងអង្គទូត និងដៃគូអភិវឌ្ឍន៍នានា*

» *ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកានៃរាជរដ្ឋាភិបាល លោកស្រី អស់លោក តំណាងស្ថាប័នពាក់ព័ន្ធ ជាទីមេត្រី!*

1. ថ្ងៃនេះ ខ្ញុំមានសេចក្ដីសោមនស្សរីករាយនិងមានកិត្តិយសចូលរួមក្នុងកិច្ចប្រជុំលើកទី១៩ នៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដោយមានឱកាសជំរាបដោយសង្ខេបជូនអង្គប្រជុំ អំពីលទ្ធផលនៃការអនុវត្តនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី ដែលសម្ដេចតេជោនាយករដ្ឋមន្ត្រីយើងខ្ញុំ បានប្រកាសជាសាធារណៈកាលពីថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ ដូចតទៅ ៖

2. អនុលោមតាមបទដ្ឋានគតិយុត្តជាធរមាន ចាប់ពីចុងខែមិថុនា ឆ្នាំ ២០១២ មក រាជរដ្ឋាភិបាល បានចាប់ផ្ដើមយុទ្ធនាការអនុវត្តបទបញ្ជាលេខ ០១ គឺ **នយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី** ដោយមានការចូលរួមរបស់មន្ត្រីក្រុមបច្ចេកទេសវាស់វែងដីធ្លី ចំនួន ១៦៦៨ នាក់ និងមានកំលាំងជំនួយរបស់យុវជនស្ម័គ្រចិត្ត ចំនួន ១៦៦៨ នាក់ (មកពីសាកលវិទ្យាល័យ វិទ្យាស្ថាន មជ្ឈមណ្ឌលបណ្ដុះបណ្ដាល រដ្ឋនិងឯកជន ចំនួន ៣៦ និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន ៣) ដែលកំពុងប្រតិបត្តិការក្នុងខេត្តចំនួន ២០ ដើម្បីវាស់វែងដីធ្លីផ្ដល់ប័ណ្ណកម្មសិទ្ធិជូនប្រជា-ពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្ដែង។

3. ទំហំសរុបប៉ាន់ស្មាននៅពេលចាប់ផ្តើម មានប្រមាណ **១ លាន ២ សែន ហិកតា** ដែលត្រូវផ្តល់ជូនប្រជាពលរដ្ឋប្រមាណ **៣៥ ម៉ឺនគ្រួសារ** និងដែលអាចមានក្បាលដីជាង **៤០ ម៉ឺនក្បាលដី** ។ តែតាមតួលេខបូកសរុបចុងក្រោយនៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២ ទំហំដីរដ្ឋដែលពាក់ព័ន្ធនឹងការកាន់កាប់មិនទាន់ស្របច្បាប់របស់ប្រជាពលរដ្ឋ កើនឡើងដល់ប្រមាណ **១ លាន ៨ សែន ហិកតា** និងចំនួនគ្រួសារកើនឡើងដល់ **៤៧ ម៉ឺនគ្រួសារ** និងដែលអាចមានក្បាលដីប្រមាណ **៧០ ម៉ឺន ក្បាលដី**។ តាមការកំណត់របស់រាជរដ្ឋាភិបាល យើងខ្ញុំចាប់ផ្តើមធ្វើការវាស់វែងដីធ្លីដែលមានទំនាស់ជាមុន ហើយជាបន្តបន្ទាប់នឹងត្រូវធ្វើការវាស់វែង រហូតដល់អស់ផ្ទៃដីដូចបានបញ្ជាក់តាមតួលេខនេះ។

4. ដីធ្លីដែលប្រជាពលរដ្ឋកាន់កាប់ជាក់ស្តែង តែពុំទាន់ស្របច្បាប់ច្បាប់នៅឡើយ ស្ថិតនៅក្នុងមុខសញ្ញាដី ០៣ ប្រភេទ គឺដីរដ្ឋក្នុងសម្បទានដីសេដ្ឋកិច្ច ដីរដ្ឋក្នុងសម្បទានព្រៃឈើ និងដីរដ្ឋដែលមានដីកាដកហូតក្នុងគម្របព្រៃឈើ។

5. ជាការពិត ដីទំហំ **១ លាន ៨ សែន ហិកតា**នេះ ពុំមែនសុទ្ធតែជាដីដែលមានទំនាស់រីកវរនោះទេ គឺដីមួយផ្នែកប្រមាណជាង **១០%** ប៉ុណ្ណោះដែលស្ថិតក្នុងដីសម្បទានសេដ្ឋកិច្ច និងដីមួយផ្នែកតូចក្នុងតំបន់ឯទៀតជាដីមានទំនាស់ជាមួយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងអ្នកកាន់កាប់ផ្សេងទៀត។ ដោយឡែក ចំពោះដីរដ្ឋដែលប្រជាពលរដ្ឋកាន់កាប់ដោយមានដីកាដកហូត និងដីរដ្ឋកាន់កាប់ឯទៀត គឺជាដីកាន់កាប់ដោយពុំទាន់ស្របច្បាប់ តែប្រជាពលរដ្ឋបានកាន់កាប់ប្រើប្រាស់ ដោយគ្រាន់តែពុំមានសុវត្ថិភាពក្នុងផ្លូវចិត្ត និងពុំទាន់ហ៊ានអភិវឌ្ឍដីធ្លីឲ្យអស់សក្តានុពលដីប៉ុណ្ណោះ។

6. ដូច្នេះជារួម **យុទ្ធនាការអនុវត្តនយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី គឺជាជំហានមួយថ្មីទៀតនៃការកែទំរង់ដីធ្លីដ៏ស៊ីជំរៅ ដើម្បីដោះស្រាយស្ថានភាពកាន់កាប់ដីធ្លីពីការកាន់កាប់ដីធ្លីមិនច្បាស់លាស់ ឬមិនទាន់ស្របច្បាប់របស់ប្រជាពលរដ្ឋ អោយមកជាការកាន់កាប់ដោយច្បាស់លាស់ ដោយសុវត្ថិភាព និងមានមូលដ្ឋានច្បាប់រឹងមាំ ដោយរដ្ឋធ្វើប្រទានកម្មឲ្យប្រជាពលរដ្ឋជាកម្មសិទ្ធិពេញលេញ ឬជាសម្បទានដីសេដ្ឋកិច្ចខ្នាតតូច ឬជាសម្បទានដីសង្គមកិច្ច** ក្នុងគោលដៅដើម្បីធានាសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ដោះស្រាយជម្លោះដីធ្លី និងជំរុញសេដ្ឋកិច្ចជាតិ តាមរយៈការគ្រប់គ្រង និងប្រើប្រាស់ដីទាំងទម្រង់ខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ ឲ្យមានប្រសិទ្ធភាព តុល្យភាព និងរក្សាបាននិរន្តរភាពបរិស្ថាន និងធនធានធម្មជាតិ។

7. ការដោះស្រាយការកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋឲ្យបានច្បាស់លាស់ ក៏ជាការធ្វើឲ្យការកាន់កាប់ដីរបស់ក្រុមហ៊ុនវិនិយោគធំតូចបានច្បាស់លាស់ផងដែរ គឺផ្ទុយនឹងការ

យល់ច្រឡំខ្លះដែលថាកិច្ចការនេះរំលោភទៅលើសម្បទានិកមួយចំនួន។ នេះ គឺជាគោលដៅពិតប្រាកដរបស់រាជរដ្ឋាភិបាល ក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចដល់ក្រុមហ៊ុន គឺចង់ឲ្យសម្បទានដីសេដ្ឋកិច្ច ផ្តល់ផលប្រយោជន៍ពិតប្រាកដដល់ប្រជាពលរដ្ឋនៅតំបន់វិនិយោគ។

8. ដោយផ្អែកលើទិន្នន័យក្បាលដីជាង **១៧ ម៉ឺនក្បាលដី** ដែលបានវាស់វែងរួចហើយមកដល់ពេលនេះ ភាគច្រើនលើសលប់ ជាក្បាលដីដែលមានទំហំក្រោម **៥ ហិកតា។** នេះសបញ្ជាក់ថា យុទ្ធនាការនេះ បំរើផលប្រយោជន៍របស់ប្រជាពលរដ្ឋតូចតាចនៅជនបទពិតប្រាកដ។

9. ដូច្នេះ **ជំហាននៃការកែទំរង់ដីធ្លីលើកនេះ អាចចាត់ទុកជាវគ្គចែកដីធ្លីដ៏ធំលើកទី ៤ ដល់ប្រជាពលរដ្ឋ (វគ្គទី១ នៅទសវត្សឆ្នាំ ១៩៨០ វគ្គទី២ បណ្តាឆ្នាំ ១៩៩១-១៩៩២-១៩៩៣ វគ្គទី៣ នៅចុងឆ្នាំ ១៩៩៨) គឺពិតជាបានបំរើផលប្រយោជន៍ពិតៗរបស់អ្នកកាន់កាប់ដីតូច និងមធ្យម។**

10. ជាទស្សនវិស័យ នៅពេលខាងមុខ ការបំពេញឲ្យគ្នាវាងអាជីវកម្មកសិកម្មរបស់អ្នកកាន់កាប់ដីខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ ពិតជានឹងក្លាយជាស្នូលនៃការរីកចំរើននៅតំបន់ជនបទ។ ការរីកចំរើននៃតំបន់ជនបទ នឹងនាំទៅដល់ការកកើតឡើងនូវទីប្រជុំជន ទីផ្សារតូចធំ នូវសហគ្រាសតូចនិងមធ្យម នូវសកម្មភាពមិនមែនកសិកម្មតាមទីក្រុងតូចៗនៅតំបន់ជនបទ ដែលនឹងមានប្រតិសកម្មជំរុញឲ្យផលិតកម្មកសិកម្មកាន់តែសំបូរបែប ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់ទីក្រុង។ សកម្មភាពមិនមែនកសិកម្មក្នុងទីប្រជុំជន នឹងស្រូបយកកម្លាំងពលកម្មនៅទំនេរនៃតំបន់ជនបទជុំវិញ ដែលជាការទប់ស្កាត់ចរន្តចំណាកទីជនបទទៅកាន់ទីក្រុង ឬទៅប្រទេសក្រៅ។

11. ជាការពិតហើយ ជាមួយនឹងការផ្តល់កម្មសិទ្ធិលើដីធ្លីដែលជាជីវិតរបស់កសិករ និងជាមូលដ្ឋាននៃការអភិវឌ្ឍ រាជរដ្ឋាភិបាលមើលឃើញការចាំបាច់ត្រូវបង្កលក្ខណៈសម្បត្តិជាមូលដ្ឋានមួយចំនួនដើម្បីបំរើដល់ការអភិវឌ្ឍ ពិសេសលក្ខណៈសម្បត្តិ ៤ គឺ ១-ផ្លូវ ២-សាលារៀន ៣-មណ្ឌលសុខភាព ៤-ដោះស្រាយបញ្ហាទឹក ដែលគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវរៀបចំផែនការអភិវឌ្ឍ និងវិនិយោគបន្ថែមលើសមិទ្ធិផលដែលមានរួចហើយនៅតំបន់នោះ។

12. ការពិត រាប់ជំនាន់មកហើយ ប្រជាជននៅតំបន់ខ្លះមិនដែលមានប័ណ្ណកម្មសិទ្ធិដីធ្លីទេ ម្លោះហើយនេះក៏ដូចជាមិនទាន់បានប្រើប្រាស់ដីធ្លីរបស់ខ្លួនជាទ្រព្យដ៏មានតម្លៃ ដែលជាផលប្រយោជន៍ជាច្រើនរបស់ដីផងដែរ។ ប្រការនេះមានមូលហេតុជាច្រើន ពិសេស

ប្រការដែលកម្ពុជាបានឆ្លងកាត់សង្គ្រាមជាច្រើនឆ្នាំ។ ទើបក្នុងទសវត្សឆ្នាំ ១៩៨០ យើងបានប្រឹងប្រែងពង្រឹងកម្មសិទ្ធិដីធ្លីដោយចេញលិខិតស្នាមរដ្ឋបាល និងប័ណ្ណភោគៈជាបន្តបន្ទាប់ រហូតមកដល់ការចេញប័ណ្ណកម្មសិទ្ធិប្រមាណ**ជាង ២ លាន ៦ សែនក្បាលដី** គិតមកដល់ខែកក្កដា កន្លងមកនេះ។

13. បច្ចុប្បន្ន ការអនុវត្តនូវនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី គឺជាសុឆន្ទៈរបស់រាជរដ្ឋាភិបាលក្នុងការធានាសិទ្ធិលើដីធ្លីរបស់ប្រជាពលរដ្ឋ ដែលយើងមើលឃើញច្បាស់ថាល្បឿននៃការចុះបញ្ជីដីធ្លីត្រូវបានកើនទ្វេដង។ ចាប់ពីពេលមានយុទ្ធនាការអនុវត្ត**នយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី** ល្បឿននៃការចុះបញ្ជីដីធ្លីជាប្រព័ន្ធ ធៀបនឹងរយៈពេលមុន គឺបានកើនឡើងទ្វេដងជាមធ្យម ដោយសម្រេចលទ្ធផលវាស់វែងប្រមាណ **៧ ម៉ឺនក្បាលដី** ក្នុងមួយខែ។

14. កិច្ចដំណើរការចុះបញ្ជីក្បាលដីទាំងនេះ គឺបានអនុវត្តយ៉ាងត្រឹមត្រូវតាមស្មារតីនៃអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពី**នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី** ហៅថា **ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ** ។ ជាចំណុចគួរកត់សំគាល់ និងជាប្រការសំខាន់ណាស់ដែលកិច្ចដំណើរការវាស់វែងដីធ្លីនេះ ត្រូវបានអនុវត្តដោយមាន**ការចូលរួមរបស់សហគមន៍**ក្នុង**គ្រប់ជំហានការងារ** តាំងពីការវាស់វែងទីតាំងតំបន់ដែលមានការពាក់ព័ន្ធ ការវាស់វែងក្បាលដីនីមួយៗ ការស្រង់ទិន្នន័យម្ចាស់ដី រហូតដល់ការបិទផ្សាយជាសាធារណៈនូវទិន្នន័យនៃក្បាលដីទាំងអស់ក្នុងទីតាំងតំបន់នីមួយៗក្នុងរយៈពេល ៣០ ថ្ងៃ សម្រាប់ទុកពេលឲ្យម្ចាស់ដី និងអ្នកពាក់ព័ន្ធ ធ្វើការផ្ទៀងផ្ទាត់ សុំកែតម្រូវទិន្នន័យ ឬតវ៉ានិងដោះស្រាយ (ផ្តល់ឱកាសឲ្យប្រជាពលរដ្ឋបញ្ចេញសំលេងតវ៉ាដោយអនុវត្តសិទ្ធិរបស់ខ្លួន និងជាឱកាសផ្តល់ឲ្យសមូហភាពធ្វើការវិនិច្ឆ័យលើទិន្នន័យដែលបានបិទផ្សាយ) រហូតបានបញ្ចប់រយៈពេលបិទផ្សាយជាសាធារណៈ និងចែកប័ណ្ណកម្មសិទ្ធិ។

15. នៅក្នុងដំណើរការនេះ ប្រសិនបើមានវិវាទកើតឡើងរវាងការកំណត់ព្រំប្រទល់តំបន់ដីរដ្ឋ និងដីដែលប្រជាពលរដ្ឋកាន់កាប់មិនទាន់ស្របច្បាប់ វិវាទនោះ ត្រូវដោះស្រាយតាមយន្តការគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត។ ដោយឡែក វិវាទដែលពាក់ព័ន្ធទៅនឹងក្បាលដី នោះត្រូវសម្រុះសម្រួលតាមរយៈគណៈកម្មការរដ្ឋបាល តាមស្មារតីអនុក្រឹត្យលេខ ៤៦ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។

16. មកដល់ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ នេះ លទ្ធផលនៃការអនុវត្ត**បទបញ្ជាលេខ ០១** នៅទូទាំងប្រទេស គិតចាប់ផ្តើមពីថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១២ មក គឺបាន

បំពេញសលាកបត្រក្បាលដីបានចំនួនជាង 240,000 ក្បាលដី កត់ក្នុងសម្រង់បញ្ជីឈ្មោះម្ចាស់ដីបានចំនួនជិត 170,000 គ្រួសារ ចំនួនគ្រួសារបានផ្ទៀងផ្ទាត់ចំនួនជិត 130,000 គ្រួសារ វាស់ក្បាលដីបានចំនួនជាង 170,000 ក្បាលដី គូរក្បាលដីបានចំនួនជាង 140,000 ក្បាលដី បំពេញទម្រង់បែបបទក្បាលដីបានចំនួនជាង 115,000 ក្បាលដី បិទផ្សាយជាសាធារណៈបានចំនួនជាង 22,000 ក្បាលដី និងចែកប័ណ្ណកម្មសិទ្ធជូនប្រជាពលរដ្ឋបានចំនួនជាង 800 ប័ណ្ណ។

17. ដោយឡែកចំពោះសិទ្ធិលើដីធ្លីរបស់ជនជាតិដើមភាគតិច គឺយើងគោរពសិទ្ធិសេរីភាពរបស់បងប្អូនជនជាតិដើមភាគតិច ដោយក្នុងការអនុវត្តនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី រាជរដ្ឋាភិបាលតាមរយៈក្រុមប្រឹក្សាគោលនយោបាយដីធ្លី បានចេញនូវសេចក្តីណែនាំ បន្ថែមលេខ ០១៥ និងលេខ ០២០ ពាក់ព័ន្ធនឹងតំបន់សហគមន៍ជនជាតិដើមភាគតិច ដែលតម្រូវឲ្យអនុវត្តតាមអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច លើកលែងតែជនជាតិដើមភាគតិចដែលមិនចូលជាសមាជិកសហគមន៍ ហើយចង់រស់នៅជាឯកជន ចាំបាច់ត្រូវមានកិច្ចសន្យាស្ម័គ្រចិត្តចង់រស់នៅជាឯកជន ដោយមានផ្តិតស្នាមមេដៃរបស់សាម៉ីជន និងសាក្សីជាជាតិពន្ធុដូចគ្នា ឬជាប្រធានសហគមន៍ ទុកជាភស្តុតាង។

18. ក្នុងយុទ្ធនាការនេះក៏បានអនុវត្តតាមការណែនាំយ៉ាងត្រឹមត្រូវនៃលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធនឹងការកំណត់ផ្លូវសាធារណៈ ទីតាំងសេវាសាធារណៈ តំបន់ព្រៃស្រោងតំបន់មូលដ្ឋានការពារប្រទេស តំបន់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ។ល។ ដែលនេះគឺជាផ្នែកមួយនៃការងាររៀបចំដែនដី។

19. ជាផ្នែកមួយនៃការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល លើការការពារធនធានធម្មជាតិ និងកិច្ចការពារបរិស្ថាន ក៏ដូចជាជួយដល់សហគមន៍មូលដ្ឋានក្នុងការទទួលបាននូវផលប្រយោជន៍ពីធនធានធម្មជាតិ រាជរដ្ឋាភិបាលបានសំរេចដកមកវិញ (និរាករណ៍ចោល) នូវដីសម្បទានសេដ្ឋកិច្ចប្រមាណជាង ៤០០០០ (បួនម៉ឺន) ហិកតា (តាមស្មារតីសេចក្តីជូនដំណឹងលេខ ៦៩៣ ស.ជ.ណ របស់គណៈរដ្ឋមន្រ្តី ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១២) ដោយផ្ទៃដីទាំងនោះស្ថិតនៅចំកណ្តាលព្រៃឡង់ ព្រៃស្រោង និងពាក់កណ្តាលស្រោង ព្រៃបៃតងជាប់ជានិច្ច តំបន់មានប្រជាពលរដ្ឋរស់នៅ តំបន់ការពារជីវៈចំរុះ ទីជម្រាលរក្សាប្រភពទឹក ច្រករបៀងសត្វឆ្លងកាត់ និងជាកន្លែងសក្តានុពលទេសចរណ៍ធម្មជាតិ។

20. ស្របនឹងលទ្ធផលវិជ្ជមានដ៏ធំធេងនៃយុទ្ធនាការដូចលើកឡើងខាងលើ កន្លងមកនេះ ក៏មានជនខិលខូច ជនឱកាសនិយមមួយចំនួន បានឆ្លៀតចូលទៅកាប់រានទន្ទ្រានដីថ្មីៗ ហើយទាមទារឲ្យអាជ្ញាធរទទួលស្គាល់។ ចំពោះករណីនេះ ខ្ញុំសុំបញ្ជាក់ថា រាល់ការកាប់រានបែបអនាធិបតេយ្យ ឬការទាមទារដីធ្លីដែលមិនបានកាន់កាប់ប្រើប្រាស់ជាក់ស្តែង ដោយគ្រាន់តែសំអាងមូលហេតុផ្សេងៗ គឺពុំអាចដោះស្រាយបានទេ។ អ្នកទាំងនោះ ត្រូវដាក់ពាក្យសុំទៅអាជ្ញាធរតំបន់ដែលមានដីសំរាប់ដោះស្រាយ តាមរយៈអាជ្ញាធរនៃតំបន់ទីលំនៅដើមរបស់ខ្លួន ឲ្យបញ្ជាក់អត្តសញ្ញាណជាគ្រួសារក្រីក្រដែលខ្វះខាតដី និងត្រូវការដីពិតប្រាកដ ដើម្បីឲ្យអាជ្ញាធរអាចដោះស្រាយនូវសម្បទានដីសង្គមកិច្ច ទៅតាមលទ្ធភាព និងទីតាំងដីធ្លីសមស្របជាក់ស្តែងដែលមាន។ នេះ ជាករណីដែលត្រូវបានចាត់ទុកជាកម្មវិធីសម្បទានដីសង្គមកិច្ចក្នុង**លក្ខណៈមិនប្រក្រតី**។

21. ខ្ញុំក៏សុំបញ្ជាក់ជូនផងដែរថា តាមរយៈយុទ្ធនាការនេះ រាជរដ្ឋាភិបាលកម្ពុជាឈានទៅកំណត់បាននូវទិន្នន័យដីរដ្ឋជាសន្និធិដីរដ្ឋ ដែលត្រូវទុកបំរុងសំរាប់ការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច។ ក្នុង**ជំហានទី២** រាជរដ្ឋាភិបាល មានកម្មវិធីរៀបចំផ្តល់ដីសម្បទានសង្គមកិច្ចក្នុង**លក្ខណៈប្រក្រតី**បន្តទៀត ដោយជំរុញល្បឿនកាន់តែខ្លាំងថែមទៀតសំរាប់គ្រួសារអតីតកងកម្លាំងប្រដាប់អាវុធ យុទ្ធជនពិការ និងគ្រួសារយុទ្ធជនពលីមរណៈ និងប្រជាជនក្រីក្រដែលខ្វះខាតដីពិតប្រាកដ។

22. ទាក់ទិននឹងការចូលរួមរបស់យុវជនស្ម័គ្រចិត្ត ខ្ញុំសូមបញ្ជាក់ថាយុវជនគឺជាកំលាំងជំនួយសំខាន់ដល់ក្រុមបច្ចេកទេសវាស់វែងដីធ្លី ដើម្បីពន្លឿនល្បឿននៃការចុះបញ្ជីដីជូនប្រជាពលរដ្ឋដែលកំពុងត្រូវការ។ តាមទិន្នន័យកន្លងមក ក៏ដូចជាការណែនាំកន្លងមក យុទ្ធនាការនេះគឺផ្តល់អាទិភាពវាស់វែងនូវក្បាលដីរបស់ប្រជាពលរដ្ឋ ដែលបានកាន់កាប់ និងដាំដុះជាក់ស្តែងតិចជាង ១០ ហិកតា ខុសពីការចោទប្រកាន់មួយចំនួនដែលថា យុវជនចុះវាស់ដីឲ្យក្រុមហ៊ុនឬវាស់ដីឲ្យអ្នកមាន។ ទន្ទឹមគ្នានេះ ការចូលរួមរបស់យុវជនស្ម័គ្រចិត្តក្នុងយុទ្ធនាការនេះ ក៏មិនប៉ះពាល់ដល់ការសិក្សារបស់ពួកគាត់ឡើយ ដោយមានមួយភាគធំជានិស្សិតដែលបានបញ្ចប់បរិញ្ញាប័ត្ររួចហើយ អ្នកខ្លះគ្រាន់តែងរង់ចាំការការពារសារណាបញ្ចប់ និងអ្នកមិនទាន់ចប់កំពុងសិក្សាឆ្នាំទី៣ ឬ ទី៤ បានសុំការអនុញ្ញាតពីសាកលវិទ្យាល័យសាមី ដើម្បីរៀនបំពេញ credit នៅពេលក្រោយបានដោយមិនខាតពេលវេលា។ លើសពីនេះទៀត និស្សិតដែលចូលរួមយុទ្ធនាការនេះ បានរៀនសូត្រច្រើនពីការអនុវត្តជាក់ស្តែង និងការចូលរួមក្នុងកិច្ចការសង្គម បំរើប្រជាពលរដ្ឋ យល់ច្បាស់អំពីជីវភាពពិតៗរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដែលនេះជាតម្លៃបន្ថែម

ដែលមិនអាចកាត់ថ្លៃបាន បន្ថែមលើចំណេះដឹងសិក្សានៅសាលាសំរាប់ជោគជ័យរបស់យុវជន នៅពេលអនាគត។

23. លទ្ធផលទទួលបានពីការចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋ ដូចបានលើកឡើងខាងលើនេះ នឹងរួមចំណែកដល់ការកំណត់ព្រំប្រទល់រវាងដីឯកជន និងដីរដ្ឋឲ្យកាន់តែច្បាស់ ព្រមទាំងអាចកសាងផែនទីដីរដ្ឋផងដែរ ដែលអាចឲ្យអាជ្ញាធរមានអាណត្តិកាន់កាប់ដីរដ្ឋ ទាំងអាជ្ញាធរថ្នាក់ក្រោមជាតិ ទាំងអាជ្ញាធរថ្នាក់ជាតិ ងាយស្រួលក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើចំណែកដីទាំងឡាយ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនកាន់តែមានប្រសិទ្ធភាព ចៀសវាងការទន្ទ្រានកាន់កាប់អនាធិបតេយ្យពីសំណាក់ជនខិលខូច។

24. ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលទាំងអស់ ដែលមានសុឆន្ទៈរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា ជាពិសេស សូមថ្លែងអំណរគុណដល់ដៃគូអភិវឌ្ឍន៍ដែលបានសហការគាំទ្រក្នុងវិស័យដីធ្លីកន្លងមក និងកំពុងបន្តសហការ។ រាល់សមិទ្ធិផលសំរេចបានដូចបានលើកឡើងខាងលើនេះ ក៏មិនអាចកាត់ផ្តាច់ពីការរួមចំណែករបស់ដៃគូអភិវឌ្ឍន៍ ដោយហេតុថាក្រោមកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូកន្លងមក កម្ពុជាបានទទួលនូវចំណេះដឹង (know-how) ការធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពរបស់មន្ត្រី ការអភិវឌ្ឍន៍ធនធានមនុស្ស ការដាក់ឲ្យមាននូវប្រព័ន្ធការងារចុះបញ្ជីដីធ្លីប្រកបដោយប្រសិទ្ធភាព ដែលទាំងនេះគឺជាលទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងដៃគូអភិវឌ្ឍន៍ស្របទៅនឹងគោលការណ៍ និងល័ក្ខខ័ណ្ឌទាំងឡាយដូចមានចែងក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស (Paris Declaration)។ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត ឆន្ទៈដ៏មោះមុត និងការទំនុកបម្រុងគ្រប់បែបយ៉ាងពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងផ្អែកលើសមត្ថភាពធនធានមនុស្ស និងប្រព័ន្ធចុះបញ្ជីដីដែលបានកសាងកន្លងមកនេះ និងភាពជាម្ចាស់ (ownership) ទើបធ្វើឲ្យយើងសំរេចបាននូវការងារជាប្រវត្តិសាស្ត្រនេះ ។

25. នៅទីបញ្ចប់ខ្ញុំ សូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ដែលបានយកចិត្តទុកដាក់ស្តាប់បទឧទ្ទេសនាមនេះ និងសូមពរដល់ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក សូមទទួលបាននូវសុភមង្គល និងជោគជ័យលើគ្រប់ភារកិច្ច។

*សូមអរគុណ!*